Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

សំណុំឯកឃ្លាំ ៣/៣ (តុលា ២០០២)៖ ១០៣-១១០



# ដើមត្នោតមានអំនួត



*លោក អ៊ួន សិលា*

មានប្រទេសមួយ លាតសន្ធឹងនៅក្នុងជ្រោយនៃទ្វីបអាស៊ីភាគអគ្នេយ៍ ដែលកាលពីដើមគេហៅថា "កម្ពុជា" ប្រែថា "ទឹកដីមាសឬសុវណ្ណភូមិ" ។ នៅក្នុងពេលនៅក្រោមអាណានិគមរបស់ប្រទេសបារាំង គេហៅប្រទេសនេះថា "កាំបូដ" ហើយឈ្មោះនោះក្រោយមកគេបានហៅជាភាសា អង់គ្លេសថា "ខេមបូឌា" ។ មានដើមត្នោតជាច្រើននៅក្នុងវាលស្រែភាគច្រើននៅក្នុងប្រទេសខ្មែរ ។ ថ្ងៃមួយក្រុមហ្វីកហ្វីនធីម៉ូថេរបស់យើងបានធ្វើដំណើរត្រឡប់មកពីបង្រៀនសិក្ខាសាលាស្តីអំពីការរួបរួមនៅក្នុងខេត្ត កំពង់ធំ ។ នៅតាមផ្លូវត្រឡប់មកភ្នំពេញវិញនោះ ក្រុមរបស់ខ្ញុំគេបានសួរខ្ញុំថា "តោះឈប់មួយភ្លែតសិន រកកន្លែងបាញ់ទន្សាយ គឺមានន័យថា រកកន្លែងបត់ជើងតូច" ។ ដូច្នេះខ្ញុំក៏បានឈប់ឡាន ហើយយើងនាំគ្នាដើររកកន្លែងគួរសម ពេលនោះខ្ញុំបានឃើញដើមត្នោតមួយដើម ដែលមានដើមឈើមួយប្រភេទទៀតដុះជាប់នៅជាមួយ ។ មើលទៅគួរឲ្យចាប់អារម្មណ៍ មែនទែន! ដើមឈើនោះ

គេបានហៅថា ដើមជ្រៃ តាមទម្លាប់ដែលគេធ្លាប់ហៅភាគច្រើននៅក្នុងប្រទេសកម្ពុជា ។

ដូចខ្ញុំបានជំរាបជូនកាលពីលើកមុននៅក្នុងអត្ថបទមួយរបស់ខ្ញុំ[១] កសិករខ្មែរមួយចំនួនបាននិយាយថា ដើមឫស្សី និង ដើមត្នោត ជាប្ដីប្រពន្ធនឹងគ្នា ។ ដើមត្នោត គឺជារុក្ខជាតិដ៏មានប្រយោជន៍បំផុត ។ ដើមវាគេអាចប្រើយកទៅធ្វើផ្ទះ ធ្វើក្រោលគោក្របី ធ្វើទូក និងធ្វើឧបករណ៍កសិកម្មដទៃទៀត។ ស្លឹកត្នោតគេអាចប្រើវាប្រកជាដំបូលផ្ទះ ឬខ្ទម ធ្វើមួក កន្ទេល ស្បោងដាក់ស្រូវជាដើម ។ ទឹកត្នោតគេយកទៅធ្វើស្ករ ផ្លែត្នោតគេយកទៅធ្វើបន្លែស្ល និងនៅពេលវាទំគេយកទៅធ្វើជានំអាកោ និងនំផ្សេងៗទៀត ។

ដូច្នេះដើមត្នោតមានប្រយោជន៍តាំងពីឫសរហូតដល់ស្លឹក គឺមានប្រយោជន៍ដូចជាដើមឫស្សីដែរ ។ ដើមត្នោតរឹង និងខ្លឹមណាស់ ។ វាមានឫសចាក់ស្រេះចូលគ្នារឹងមាំជាទីបំផុត ។ កម្រមានខ្យល់ព្យុះណាអាចធ្វើឲ្យដើមត្នោតរលំណាស់ ។ ស្លឹកត្នោតមានពណ៌បៃតងចាស់រហូតពេញមួយឆ្នាំ គឺពណ៌វាស្រដៀងនឹងពណ៌ដើមស្រល់ ឬដើមណូអែលដែរ ។ ពណ៌វាមិនប្រែប្រួលឡើយ ទោះជារដូវណាក៏ដោយ ។ ហេតុដូច្នេះហើយ ទើបម្ចាស់សណ្ឋាគារលំដាប់ផ្កាយប្រាំខ្លះ និងម្ចាស់អាគារទំនើបៗមួយចំនួនដទៃទៀតនៅក្នុងទីក្រុងភ្នំពេញ គេបានយកដើមត្នោតមកដាំដើម្បីលំអនៅក្នុងទីធ្លាខាងមុខអាគារទាំងឡាយនោះ ។ ដើមត្នោតទាំងឡាយនោះមិនគ្រាន់តែបន្ថែមសម្រស់ដល់សណ្ឋាគារប៉ុណ្ណោះទេ ប៉ុន្តែជួយរំលឹកដល់មនុស្សដែលកំពុងរស់នៅក្នុងសង្គមខំប្រដេញជើងគ្នាដើម្បីរស់នៅក្នុងទីក្រុង ឲ្យគេនឹកឃើញដល់ជីវិតរស់ដែលប្រកបដោយសេចក្ដីសុខរបស់កសិករខ្មែរយើងនៅតាម

---

[១] *ដើមឫស្សី នៅក្នុងសំណុំទឹកឃ្មុំ លេខ២/២ ឆ្នាំ ២០០២ ។ នៅត្រង់ទំព័រ១០-១៥ ។*

ជនបទ ។ កាលពីសម័យបោះឆ្នោតឆ្នាំ១៩៩៨ មានគណៈបក្សនយោបាយមួយបានជ្រើសយកដើមត្នោតមកធ្វើជានិមិត្តសញ្ញារបស់គណៈបក្ស ។ ប្រហែលជាគេយល់ឃើញថា គេអាចធ្វើឲ្យប្រជាជនខ្មែរចាប់អារម្មណ៍លើភាពរឹងមាំរបស់ដើមត្នោត ហើយនិងភាពមិនប្រែប្រួលនៃពណ៌របស់ស្លឹកត្នោត និងអាចយល់ចិត្តរបស់ប្រជារាស្ត្រខ្មែរ ដើម្បីឲ្យគេបោះឆ្នោតឲ្យ ។

ខ្ញុំផ្ទាល់ក៏យល់ស្របតាមគំនិតបែបនោះដែរ! ព្រោះវិចិត្រករខ្មែរភាគច្រើនតែងតែមានអារម្មណ៍ស្រដៀងគ្នានេះដែរ គឺនៅក្នុងគំនូររបស់គេដែលបង្ហាញពីទេសភាពនៅតាមជនបទស្រុកស្រែនោះ គេតែងតែគូររូបដើមត្នោតនៅក្នុងរូបនោះដែរ ។ ដើមត្នោតជារុក្ខជាតិមួយដែលរឹងមាំ និងមានប្រយោជន៍បំផុតនៅក្នុងប្រទេសខ្មែរ ។ ដើមត្នោតអាចឈររឹងមាំបានមិនថាឡើយនៅពេលទឹកជន់ឬមានខ្យល់ព្យុះនោះទេ ឬនៅក្នុងរដូវប្រាំងរាំងស្ងួតយ៉ាងណាក្តី ហើយមិនតែប៉ុណ្ណោះដើមត្នោតជានិមិត្តសញ្ញានៃដើមឈើតំណាងឲ្យប្រទេសជាតិទៀតផង ។

ប៉ុន្តែដើមត្នោតនឹងងាប់ បើសិនជាមានដីកខ្វក់នៅជាប់នឹងដើមនោះ ទោះបីជាដើមត្នោតរឹងមាំយ៉ាងណាក្តី និងមានមោទនភាពនឹងសម្រស់របស់ខ្លួនយ៉ាងណាក្តី ។ បើសិនកសិករមិនមកកាត់គាវត្នោតចាស់ៗចេញទេ គាវត្នោតទាំងនោះនឹងមានជាប់ដី ហើយដីនោះនឹងកកនៅតាមគាវត្នោត ។ មានសត្វស្លាបជាច្រើន ដែលតែងតែពាំយកផ្លែឈើយកទៅស៊ីនៅលើគាវត្នោត ឬក៏ជុះអាចម៍នៅលើនោះ ។ នៅពេលមានភ្លៀងធ្លាក់មក អាចម៍សត្វដែលមានគ្រាប់រុក្ខជាតិនោះក៏ដុះឡើង ។ ពេលមុនដំបូង ពេលដែលដើមរុក្ខជាតិនោះដុះភ្លាមឃើញតូចមែនទែន ដែលដើមត្នោតគិតថា វាមិនមានការគំរាមកំហែងអ្វីដល់ខ្លួនវាឡើយ ។ ប្រហែលជាដើមត្នោតមានមោទនភាពខ្លួនឯងថា ខ្លួនមានសម្រស់កាន់តែស្រស់មួយកំរិតទៀត នៅពេលដែលខ្លួនមានដើមរុក្ខជាតិមួយប្រភេទទៀតមកដុះនៅជាមួយនោះ ។

ប៉ុន្តែមិនយូរប៉ុន្មាន ដើមរុក្ខជាតិនោះកាន់តែដុះធំឡើងៗជាលំដាប់ ។ ដើមត្នោតមិនអាចទទួលយកជីវជាតិដែលឫសរបស់ខ្លួនខំក្រេបជញ្ជក់ពីដីមកចិញ្ចឹមខ្លួនបានទេ ព្រោះជីជាតិទាំងឡាយនោះត្រូវបានរុក្ខជាតិមួយបែបទៀតជញ្ជក់យកអស់ ។ ដើមត្នោតក៏ចាប់ផ្តើមកើតជម្ងឺកង្វះជីវជាតិ ហើយក្រោយមកមិនយូរប៉ុន្មានក៏ស្លាប់តែហោងតែម្តងទៅ ។ នៅពេលដែលយើងទៅចូលរួមការប្រជុំបំប៉នស្មារតីបុគ្គលិកអង្គការ ទស្សនៈ ពិភពលោក (World Vision Staff retreat) នៅក្នុង ខេត្តសៀមរាប កាលពីពីរឆ្នាំមុន យើងបានទៅទស្សនាប្រាសាទអង្គរវត្ត ។ ខ្ញុំបានសង្កេតមើលទៅតាមកំផែងនៃប្រាង្គប្រាសាទទាំងឡាយនោះ ត្រូវទទួលរងនូវការបំផ្លិចបំផ្លាញដោយសារឫសឈើ ដូចដែលខ្ញុំធ្លាប់ឃើញដុះនៅតាមដើមត្នោតនោះដែរ ។ ឫសរុក្ខជាតិនោះវាបានញែកបំបែកផ្ទាំងសិលា ដែលដូនតារបស់យើងបានដាក់នៅជាប់ជិតគ្នានោះឲ្យឃ្លាតពីគ្នា ។ កំផែងប្រាង្គប្រាសាទទាំងនោះមើលទៅមានសោភ័ណភាពល្អប្រណិត ដរាបណាវានៅជាប់ស្អិតជាមួយគ្នា ហើយក្បាច់ចម្លាក់ដ៏រស់រវើកទាំងនោះ ឆ្លុះបញ្ចាំងពីស្នាដៃដ៏ប្រពៃរបស់បុព្វបុរសខ្មែរយើង ដែលមានអារិយធម៌ដ៏រុងរឿងនៃអធិរាជខ្មែរ ។ ដើម្បីជួយសង្គ្រោះប្រាង្គប្រាសាទទាំងនោះមិនឲ្យខូចខាត នោះក្រសួងទេសចរណ៍ត្រូវចាត់ឲ្យមានកម្មករទៅកាត់ឫសរុក្ខជាតិនោះចេញ ។ ប្រាង្គប្រាសាទបុរាណទាំងនោះភាគច្រើនទទួលរងនូវការខូចខាតដោយសារតែឫសឈើ ដែលដុះជ្រៀតនៅត្រង់ចន្លោះកណ្តាលផ្ទាំងសិលានីមួយៗ ។ ដើមឈើទាំងនោះដុះត្រគោលត្រគុំក្នុងពេលដែលស្រុកខ្មែរកើតសង្គ្រាមក្នុងស្រុកអស់រយៈពេលយ៉ាងយូរ ដែលពេលនោះគ្មានអ្នកទេសចរណ៍ណាម្នាក់ហ៊ានទៅទស្សនាប្រាង្គប្រាសាទនោះឡើយ ។ ប្រទេសកម្ពុជា ត្រូវបានកាត់ផ្តាច់ចេញពីពិភពលោកជិតពីរទសវត្សរ៍ ។ មិនថាឡើយអ្នកទេសចរណ៍មកពីក្រៅប្រទេស សូម្បីតែអ្នកទេសចរណ៍នៅក្នុងស្រុកក៏មិនអាចទៅទស្សនាប្រាង្គប្រាសាទទាំងនោះ

បានឡើយ ដោយសារសម័យកាលវាលពិឃាត ។ កាលពីសម័យនោះ មិនថាឡើយជីវិតមនុស្សទទួលរងនូវការកាប់សម្លាប់ សូម្បីតែថ្នាំងសិលាក៏ត្រូវទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរដែរ ។

រឿងទាំងឡាយខាងលើនេះ ធ្វើឲ្យខ្ញុំនឹកឃើញពីទំនាក់ទំនងដែលព្រះជាម្ចាស់ហើយនិងប្រជារាស្ត្ររបស់ព្រះអង្គធ្លាប់មានភាពជិតស្និតពីមុនមកនោះ ។ កាលដើមដំបូងឡើយ មនុស្សនិងព្រះជាម្ចាស់ជាគូកនយ៉ាងជិតស្និតជាមួយគ្នា ប៉ុន្តែបន្ទាប់ពីអាដាំ និងអេវ៉ា ធ្លាក់ក្នុងអំពើបាប ពេលនោះហើយដែលអំពើបាបបានចូលទៅក្នុងពិភពលោកយើងនេះ ហើយថែមទាំងបានញែកមនុស្ស និងព្រះអាទិកររបស់ខ្លួនឲ្យឃ្លាតពីគ្នា ។ ដ្បិតឈ្នួលនៃអំពើបាបនោះគឺសេចក្តីស្លាប់ ។ ដើម្បីជួសជុលនូវទំនាក់ទំនងដែលបានបាក់បែកនោះ ដំបូងយើងត្រូវដោះស្រាយជាមួយអំពើបាបជាមុនសិន ។ មិនខុសគ្នានឹងការជួសជុលកំផែងប្រាង្គប្រាសាទអង្គរវត្តនោះឡើយ ។ ដើម្បីជួសជុលក្រសួងទេសចរណ៍ត្រូវបញ្ជូនមនុស្សឲ្យទៅកាត់ផ្តាច់ឫសឈើជាមុនសិន ។ កាលពីដំបូងឫសឈើទាំងនោះដុះឡើងតូចៗបំផុត ប៉ុន្តែនៅពេលយូរៗទៅវាក៏កាន់តែធំឡើងៗជាលំដាប់ ។ កាលណាទុកវានៅកាន់តែយូរ ការខូចខាតដល់រូបចម្លាក់នោះ កាន់តែធ្ងន់ធ្ងរ ។

អំពើបាប នៅពេលដែលវាចាប់ផ្តើមកើតឡើងដំបូង គឺវាតូចបំផុត ប៉ុន្តែនៅពេលដែលយើងទុកពេលឲ្យវាកន្លងហួសទៅកាន់តែយូរ គឺវាកាន់តែធ្ងន់ធ្ងរឡើងៗ ។ អំពើបាបដែលយើងមិនបានលន់តួ នោះនឹងធ្វើឲ្យខូចដល់ទំនាក់ទំនងផ្សេងៗ ។ នៅក្នុងនាមយើងជាគ្រីស្តបរិស័ទ សូមឲ្យយើងនឹកចាំពីមេរៀនដែលយើងរៀនបានពីដើមត្នោត ។ សូមកុំឲ្យយើងមានអំនួតថាយើងរឹងប៉ឹង ដែលថាយើងជាដើមត្នោត ជានិមិត្តសញ្ញានៃប្រទេសជាតិ ឬក៏គិតថា ជារាស្ត្រដែលព្រះជាម្ចាស់ជ្រើសរើស ឬពូជសាសន៍ពិសេស និងគិតថាយើងមានមុខមាត់ ព្រោះមានគេត្រូវការយើងច្រើនយកទៅលំអ

សណ្ឋាគារថ្នាក់ផ្កាយ៥នោះឡើយ ។ កុំឲ្យយើងរំភើបនឹងលំអ និងកិត្តិយស ដែលយើងបានទទួលនោះឡើយ ។ បើសិនជាភ្លេចខ្លួន មិនអនុញ្ញាតឲ្យអ្នកថែសួនមកកាត់គាវចាស់ៗចេញពីយើងទៅទេនោះ យើងនឹងមានភាពកខ្វក់ ជិតជាប់នៅជាមួយយើង ពេលនោះនឹងមានសត្វស្លាបជុះអាចម៍ដាក់លើយើង ។ ដូចជាសុភាសិតអង់គ្លេសមួយឃ្លា ដែលគេចែងរំលឹកយើងថា៖ "យើងមិនអាចបញ្ឈប់សត្វស្លាបពីការហើររំលងក្បាលយើងបានទេ ប៉ុន្តែយើងអាចបញ្ឈប់វាមិនឲ្យធ្វើសំបុកនៅពីលើក្បាលយើងបាន" ។

យើងត្រូវតែលន់តួអំពើបាបរបស់យើងទៅព្រះជាម្ចាស់ ។ តែនៅពេលដែលយើងព្រមលន់តួបាបរបស់យើងដល់ព្រះអង្គវិញ នោះព្រះអង្គសន្យាថានឹងប្រព្រឹត្តចំពោះយើងយ៉ាងសុចរិត គឺព្រះអង្គនឹងអត់ទោសរាល់អំពើបាបរបស់យើង និងសំអាតយើងពីការទុច្ចរិតទាំងឡាយផង ។[២] បើសិនជាយើងអនុញ្ញាតឲ្យអំពើបាបដុះដាលកាន់តែធំឡើងៗ នោះយើងមិនអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់បានឡើយ យើងនឹងត្រូវវិនាសដូចជាដើមត្នោតដែរ ។

ដូចគ្នានេះដែរ រាល់ទំនាក់ទំនងផ្សេងៗរវាងមិត្តសម្លាញ់ និងរវាងក្រុមជំនុំ បើសិនជាយើងទុកឲ្យអំពើបាបដុះខណ្ឌយើងនោះ គឺវាអាចកើតឡើងនូវភាពរីករវដូចពោលខាងលើនោះបាន ។ ទំនាក់ទំនងរបស់យើងនឹងត្រូវរលំដួល ដូចជាផ្ទាំងថ្មនៅតាមកំផែងនៃប្រាង្គប្រាសាទអង្គរវត្តដែរ ។ ចូរប្រយត្ន័ឫសដែលដុះនៅចន្លោះផ្ទាំងសិលានានា ដែលស្លាបត្បូងរបស់យើងគេបានដាក់ឲ្យនៅជាប់ស្អិតជាមួយគ្នា ។ នៅពេលដែលវានៅជិតគ្នាទើបវាអាចក្លាយទៅជាបាយ័នមុខបួន ឬជារូបអប្សរាបាន និងអាចមើលទៅស្រស់ស្អាតទៅបានដែរ ។ ប៉ុន្តែបើមានឫសឈើទៅដុះនៅចន្លោះរូបភាពដើម

---

[២] ១យ៉ូហាន ១:៩

ដែលយើងកោតសរសើរថាស្រស់ស្អាត នោះនឹងលែងស្រស់ស្អាតទៀតហើយ ។ មិនគ្រាន់តែមើលទៅមិនស្រស់ស្អាតប៉ុណ្ណោះទេ គឺតួប្រាសាទទាំងមូលអាចនឹងត្រូវខូចបង់ទៅទៀតផង ។ ដូច្នេះ ចូរចាំឲ្យបានច្បាស់ថាត្រូវកាត់ឫសឈើចោលចេញ ។

បងប្អូនអើយ ព្រះយេស៊ូសព្វព្រះហឫទ័យជួយជួសជុលទំនាក់ទំនងដែលបាក់បែករវាងមនុស្សជាតិទាំងឡាយនោះឡើងវិញ ។ ព្រះជាម្ចាស់ និងមនុស្សធ្លាប់មានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និតបំផុត ។ ប៉ុន្តែដោយសារតែអំពើបាបបានញែកមនុស្សយើងឲ្យដាច់ចេញពីព្រះអង្គ និងធ្វើឲ្យមានការបាក់បែកប្រេះឆាផ្នែកទំនាក់ទំនងនេះ ។ ពីព្រោះតែទំនាក់ទំនងដ៏សុក្រឹតរវាងព្រះជាម្ចាស់ និងមនុស្សត្រូវបាក់បែក ដូច្នេះហើយទើបរាល់ទំនាក់ទំនងទាំងឡាយក៏ត្រូវប្រែជាមិនល្អទាំងអស់ផងដែរ ។ ទំនាក់ទំនងនោះរួមមានទំនាក់ទំនងរវាងប្ដីនិងប្រពន្ធ កូននិងឪពុកម្ដាយ ចៅហ្វាយនិងកូនចៅ បងនិងប្អូន ប្រជាជាតិនិងប្រជាជាតិ ពូជសាសន៍និងពូជសាសន៍ ។ល។ បានក្លាយទៅជាជូរជ្រួម និងមានភាពរញ៉េរញ៉ៃអស់ទៅ ។ ហេតុអ្វី? គឺវាបណ្ដាលមកពីអំពើបាប ។ ប្រជាជន ជាតិសាសន៍ និងសង្គមទាំងអស់អាចរស់នៅដោយសុខដុមរមនាជាមួយគ្នា បើសិនជាគេព្រមអនុញ្ញាតឲ្យព្រះយេស៊ូកាត់ឫសគល់នៃអំពើបាបនោះចេញ ។ មានតែព្រះនាមព្រះអង្គតែមួយគត់ដែលអាចជួយសង្គ្រោះដល់មនុស្សលោកទាំងអស់បាន [៣]។ ព្រះអង្គជាកសិករ ដែលជួយសំអាតដើមត្នោតពីការរុករានទន្ទ្រានពីសំណាក់រុក្ខជាតិផ្សេងៗ ដែលបំផ្លាញដល់ការរីកដុះដាលរបស់ដើមត្នោត ។ ព្រះអង្គក៏ជាភ្នាក់ងារពីក្រសួងទេសចរណ៍ ដែលជួយកាត់ឫសឈើចេញពីចន្លោះផ្ទាំងសិលារបស់ប្រាង្គប្រាសាទដែរ ។

---

[៣] *កិច្ចការ៤:១២*

សរុបសេចក្ដីៈ

- ដើមត្នោតអាចរស់នៅយូរអង្វែងនិងរឹងមាំបាន បើគ្មានដើមជ្រៃ ឬរុក្ខជាតិផ្សេងទៀតដណ្ដើមដុះពីលើវាទេនោះ ។
- គ្រីស្ទបរិស័ទអាចឈររឹងមាំក្នុងជំនឿរបស់ខ្លួនបាន បើសិនមិនព្រមឲ្យអំពើបាបរីកដុះដាលនៅក្នុងជីវិតរបស់គេ ។
- ផ្ទាំងសិលានៅក្នុងប្រាង្គប្រាសាទអាចមើលទៅស្រស់ស្អាត បើសិនជាផ្ទាំងសិលាទាំងនោះស្ថិតនៅកៀកកិតនឹងគ្នាតាមទំរង់ដើមដែលគេបានដាក់វាឲ្យនៅនោះ ។
- រាល់ទំនាក់ទំនងទាំងឡាយអាចមានភាពសុខដុមរមនាទៅបាន បើសិនជាយើងព្រមដោះស្រាយអំពើបាបជាមុនសិននោះ ។

HONEYCOMB 3/3 (October 2002): 111–114



# The Proud Palm Tree



*UON Seila*

On a peninsula in Southeast Asia lies a country once called "Kampuchea," meaning "The Land of Gold." During the colonial period the French called it "Cambodge," a name that later evolved into "Cambodia." There are a lot of palm trees in most farming fields in Cambodia. One day our Training of Timothys team was returning from a seminar on unity in Kompong Thom. On the way back to Phnom Penh my team asked me, "Let's stop for a while to shoot a rabbit (i.e., find a rest room)." So I stopped the car and we went to "shoot a rabbit" or "see a man about a dog," and I noticed a palm tree with another kind of tree growing on it. That was interesting! The tree was called *Chrey* in Cambodian.

As I mentioned in a previous article,[1] some Cambodian farmers consider the bamboo and palm tree to be husband and wife. The palm tree is very useful. It can be used for building houses, barns, boats, and farming tools. Its leaves can be used to thatch roofs, make hats, mats, containers for rice crops, etc. Its juice can produce sugar, its fruit can be cooked as food, and when it ripens the palm can be used to make *Akor* and other kinds of cake.

---

[1]Uon Seila, "Bamboo," *Honeycomb* 2/2 (April 2001): 10–15.

So the palm tree is very useful from root to leaves, just as is the bamboo. Its trunk is strong and hard. It has sturdy roots. Storms only rarely can cause a palm tree to fall. Its leaves look dark green all year round, similar to a pine tree or Christmas tree. It does not change color as the seasons pass. That is why owners of some five-star hotels and other buildings in Phnom Penh plant palm trees in their yards as decorations. They not only add beauty to the hotel, but also invite people caught up in a rat-race society to think about the peaceful countryside lives of Cambodian farmers. In the 1998 election one political party chose the palm tree as its emblem. Perhaps they thought they could focus the attention of the Khmer people on the strength of the tree and the unchanging evergreen color of its leaves, and so win people's hearts and votes.

I also agreed with that idea! Most Cambodian artists express similar feelings by including palm trees in their paintings of countryside scenery. The palm tree is a strong and useful plant in Cambodia. It can stand firm whether in flood or in storm or in dry season, and it also stands symbolically as a national tree.

But the palm tree will die if there is some dirt on it, even though it is so proud with its beauty and its strength. If the farmer does not come to cut the leaves and they stay attached, some dirt may accumulate where they attach to the trunk. Birds will drop into this dirt on the palm tree their stools carrying seeds of fruits they have eaten. When the rainy season comes, these small seeds will germinate and grow. At first they look too small to bother the tall palm tree. Maybe the palm even looks proud of having two kinds of tree growing together.

But as the years fly by the other tree grows bigger and bigger. Eventually the palm can't get enough of the nutrients that its roots absorb from the ground because the other tree sucks them all away. The palm tree then becomes malnourished, and before long dies.

When we had World Vision staff retreat in Siem Reap two years ago we visited a ruined temple. I noticed that some of the temple walls had been destroyed by the same kind of tree I saw growing on the palm tree. Its root had split the stones from sticking close together. As long as the stones stayed close together the wall looked good, and the beauty of each relief it bore vividly reflected the civilization of the Khmer

Empire. In order to save the temple from falling apart the Ministry of Tourism had workers cut the root of the tree away. Most of the ruin was destroyed by a root that grew between the stones of the temple. These trees had flourished during the long years of the civil war when no visitors came to see the temple. Cambodia was cut off from the world for nearly two decades. Neither local nor overseas visitors came to the temples during the time of the killing fields. So not only were people killed during that time, even the stones were badly damaged.

It reminded me of the relationship that God and his people once enjoyed. In the beginning man and God were close companions, but after the fall of Adam and Eve, sin entered this world and separated man from his creator. For the wages of sin is death. In order to fix the broken relationship sin must be dealt with first. It is like the stone wall at Angkor Wat. To save it from destruction they need to send some agent from the Ministry of Tourism to cut the root. When it first started growing the root looked very small, but as time went by it grew bigger and bigger. The longer it stayed the worse the damage it caused to the relief.

Sin at first starts very small, but as time passes its results grow worse and worse. Unrepented sin will ruin a relationship. As Christians please remember the lesson from the palm tree. Don't be proud that we are strong, that we the palm tree are the symbol of the country—the chosen race or kin, and that they use us to decorate five-star hotels. Don't be thrilled with the beauty and honor that we are given. If we forget to allow garden keeper to take away our old leaves we will become dirty, or birds will drop something on us. As an English saying reminds us, "We cannot stop birds from flying over our heads, but we can stop them from building their nests on our heads."

We have to confess our sins to God. But if we confess our sins to God, he will keep his promise and do what is right: he will forgive us our sins and purify us from all our wrongdoing.[2] If we allow sin to grow bigger and bigger we can never come into the presence of the Lord and we will perish like a palm tree.

---

[2] 1 John 1:9.

The same can happen in the relationships between friends and churches if we allow sins to grow between us. Like the stone wall at Angkor Wat, our relationship will fall apart. Beware of roots that start to grow between the stones that the builder originally placed close together. When the stones remain close together, they become the image of the four faces at Bayon or Apsara, and they look beautiful. But when tree roots grow in between, the original shape with its beauty and meaning is lost. Not only does it look ugly, but the whole temple may fall as well. Make sure you cut away the roots.

My friends, Jesus wants to fix the broken relationship with all humankind. God and man used to have a very close relationship. But sin separated us from God, and caused that relationship to break down. Because the sacred relationship between God and man broke, all other types of relationships have turned sour as well. Relationships between husband and wife, children and parents, brothers and sisters, nation and nation, race and race, etc., became spoiled and turned into a mess. Why? It is caused by SIN. But people, races, and societies can live in harmony if they allow Jesus to cut off the root of sin. He is the only name that can save mankind.[3] He is the farmer who can clean the palm tree to keep it from being destroying by an invading plant. He is the agent from the Ministry of Tourism who can dig out the roots growing between stones of the ruin.

Conclusion:

- Palm trees can live long and stay strong if they have no other tree growing in their stem.
- Christians can stand strong in their faith if they don't allow sin to grow bigger and bigger in their lives.
- Stones in old ruins can still look beautiful if they stay close to the original place where they were put.
- All kinds of relationships can be in harmony if sin is dealt with first.

---

[3]Acts 4:12.